# ការសំភាសន៍របស់អ្នកមីង ជួន ផល្លី

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ជួន ផល្លី

## ការសង្ខេបប្រវត្តិរបស់អ្នកមីង ជួន ផល្លី

អ្នកមីង ជួន ផល្លី មានអាយុ51 ឆ្នាំនៅក្នុងឆ្នាំ2018 អ្នកមីង ជួន ផល្លី មានភេទស្រី អ្នកមីង ជួន ផល្លី មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកតាន្ទ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។

កៈ ចឹងសំរាប់ជាដំបូងខ្ញុំអរគុណមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍ទាំងអស់មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឳពុកម្តាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍មីង ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ហាសមីងចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ យល់ព្រមកន្លែងណាដែរខ្ញុំចងចាំបានខ្ញុំប្រាប់

កៈ បាទមីងខ្ញុំចង់និយាយមួយនឹងមីងចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍មីងគឺនៅថ្ងៃទី22 ខែ3 ឆ្នាំ2018 ហើយការសំភាសន៍ទាំងអស់នេះត្រូវបានធ្វើនៅភូមិ ចុះភូមិនឹងភូមិអីគេដែរមីង?

ខៈ ភូមិព្រៃកតាន្ទនឹងភូមិព្រៃកតាន្ទ

កៈ នៅភូមិព្រៃកតាន្ទ2ហីមីង?

ខៈ មិនដឹងថាភូមិព្រៃកតាន្ទ1រឺមួយក៏ភូមិព្រៃកតាន្ទ2ទេនេះដូចថា2រឺ1ដែរចាន់ណាអត់ច្បាស់ដែរនឹង

កៈ ដឹងតែនៅភូមិព្រៃកតានួណាមីង?

ខៈ ចា៎!!នឹងហើយ

កៈ នៅភូមិព្រៃកតានួ
ចុះឃុំវិញគេមានដាក់ឃុំអីទេមីងរឺមួយគេសង្កាត់យកតែម្តងហោសមីង?

ខៈ នៅសង្កាត់ចាក់អង្រែលើ

កៈ សង្កាតចាក់អង្រែលើ នៅខ័ណ្ឌ?

ខៈ នៅខ័ណ្ឌមានជ័យ

កៈ នៅខ័ណ្ឌមានជ័យ នៅរាជធានៅភ្នំពេញ
បាទមីងចឹងសំរាប់ឈ្មោះពេញរបស់មីងនឹងមានឈ្មោះ អីគេដែរមីង?

ខៈ រាល់ថ្ងៃនឹងខ្ញុំឈ្មោះជួន ផល្លី

កៈ មីងឈ្មោះជួន ផល្លី ចុះមានឈ្មោះហៅក្រៅដែរទេមីង?

ខៈ អត់មានទេ មានតែឈ្មោះប៉ុណ្ណឹងគេហៅតែឈ្មោះជួន
ផល្លីចឹងហើយហើយបងប្អូននឹងហៅតែឈ្មោះអាលីៗៗចឹងតែម្តងនឹង

កៈ អ៎ូៗៗ!បាទមីងចុះកាលពីនៅក្មេងនឹងមាននរណាហៅឈ្មោះមីងអីផ្សេងទៀតទេ?

ខៈ អត់មានទេ

កៈ ចឹងអត់មានទេណាមីង ចុះសព្វថ្ងៃនឹងមីងអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំអាយុ51ឆ្នាំនឹង

កៈ អ៎ូ!!មីងអាយុ51ឆ្នាំ ចុះមីងកើតនៅឆ្នាំណាដែរទៅមីង?

ខៈ ខ្ញុំកើតនៅឆ្នាំ1968

កៈ ចឹងនៅឆ្នាំ 1968ណាមីង ចុះថ្ងៃខែមីងមានចងចាំទេមីង?

ខៈ ថ្ងៃខែយើងចេះតែដើរដាក់ផ្តេសផ្តាស់នឹងអត់ចងចាំទេ?

កៈ អ៎ូ!!ចឹងមានន័យថាយើងអត់ប្រាកដទេណាមីង?

ខ៖  យើងអត់ប្រាកដទេពីព្រោះយើងអត់ដឹងទេនឹង

ក៖  អូ៎!!បាទចឹងសំរាប់មីងឆ្នាំច័ន្ទគតិនឹងមីងឆ្នាំអីគេដែរមីង នៅឆ្នាំជូត ឆ្លូវ ខាល ថោះអីហាសមីង?

ខ៖  ខ្ញុំឆ្នាំមមែ

ក៖  ចឹងមីងឆ្នាំមមែណាមីង ចុះមីងដូចជាមីងកើតនៅណាដែរមីង?

ខ៖  កាលណុងខ្ញុំកើតនៅទីក្រុងភ្នំពេញនឹងសង្កាត់លេខ5

ក៖  ប៉ុន្តែភូមិ ឃុំនឹងមានទេ?

ខ៖  អត់ដឹងថាភូមិឃុំអីទេនឹង ដឹងតែមានសង្កាត់លេខ5នឹង ទីក្រុងភ្នំពេញនឹង

ក៖  ខ័ណ្ឌនឹងក៏អត់ដឹងថាខ័ណ្ឌអីគេដែរ?

ខ៖  អត់ដឹងដែរនឹងហាស

ក៖  អូ៎!!បាទមីង ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖  មីងមានបងប្អូននឹងដូចជាច្រើនដែរនឹងហាសមានប្រហែលជា9នាក់នឹងហើយ

ក៖  មានបងប្អូន9នាក់ ប៉ុន្តែពួកគាត់នៅរស់ទាំងអស់គ្នាដែរតើហីមីង?

ខ៖
ពួកគាត់ស្លាប់អស់ហើយបែកបាក់គ្នាអស់រលីងហើយតាំងពីជំនាន់ពលពតនឹងបែកគ្នាទាំងអស់នឹង

ក៖  ចឹងមានន័យថានៅសល់តែមីងម្នាក់ឯងមួយទេមែនមីង?

ខ៖  នៅសល់នឹងបែកនៅឆ្នាំ1980នឹង
នៅមានបងប្អូន2នាក់ដល់ពេលដែរមាន2នាក់នឹងមកជួបគ្នា
នៅក្នុងឆ្នាំ1988នឹងមានបានជួបគ្នា2នាក់ទៀតនឹង

ក៖  ចឹងមានន័យថាឥឡូវនឹងនៅសល់5នាក់?

ខ៖  អត់ទេនៅសល់4នាក់នឹង

កៈ ចឹងនៅសល់តែ4នាក់ទេ?

ខៈ ដល់ពេលនៅសម័យនេះបានស្លាប់អស់2នាក់ទៀតនឹងនៅសល់តែ2នាក់ទេឥឡូវនឹង

កៈ អូ៎!!ចឹងនៅសល់តែ2នាក់ទេណាមីង?

ខៈ ចា៎!!!នឹងហើយ

កៈ ចុះមីងមានចងចាំថាកាលណុងបងប្អូនរបស់មីងនឹងមានស្រីប៉ុន្មាននាក់ ហើយនឹងប្រុសមានប៉ុន្មាននាក់ដែរមីង?

ខៈ ភ្លេចអស់ហើយនឹងដូចជាមានស្រី5នាក់ក៏មិនដឹងដែរនឹងហារដូចជាមានប្រុសច្រើនជាងតិចនឹង

កៈ មាន9នាក់ចឹងមានន័យថាមានប្រុស5នាក់នឹងស្រី4នាក់ណាមីង?

ខៈ ចា៎!!មិនដឹងថា9នាក់រឺមួយក៏10នាក់ទេនេះខ្ញុំចងចាំអត់ច្បាស់ទេ ពីព្រោះអីនឹងខ្ញុំនៅតូចៗដែរនឹងហាស

កៈ បាទមីងបាទ?

ខៈ ដល់ចឹងគាត់បែកគ្នាតៅសម័យពលពតអស់ហើយនឹងទៅមានទៅ4នាក់ ដល់ពេលគេបានដក2នាក់ទៀតចឹងនៅសល់តែ2នាក់ទេនឹង

កៈ បាទមីងបាទ?

ខៈ ហើយដល់ពេលដែរបាត់2នាក់នឹងទៅនឹងខ្ញុំនៅ2នាក់តូចៗនឹងមកនៅសម័យឆ្នាំ1980នឹងចូលឆ្នាំ1987-19788នឹងបានជួបគ្នា2នាក់ទៀតនឹងដល់ពេលដែរបានជួបគ្នា2នាក់នឹងទៀតក៏បានបែកគ្នា2នាក់នឹងទៀតមកនឹង

កៈ បាទមីងបាទនឹង?

ខៈ បែកលក្ខណះស្លាប់នឹងតែម្តងនឹងហាស នឹងដឹងថាគាត់ស្លាប់នៅជាក់ស្តែងនឹងតែម្តងនឹង

កៈ បាទមីងនបាទ?

ខៈ ក្រៅពីនឹងទៅអត់ដឹងទេក្មួយ

កៈ អូ៎!!ចឹងមានន័យថាប៉ុន្តែមីងមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខៈ បងៗៗដែរស្លាប់នឹង

កៈ បងៗៗដែរស្លាប់នឹងអ្នកដែរនៅរស់ទាំងអស់នឹងមីងចងចាំបានប៉ុណ្ណាទៅមីង?

ខៈ មីងនៅចងចាំថាបងទី1នឹងឈ្មោះកាន បងទី2នឹងឈ្មោះគីម ដល់ពេលទី3នឹងឈ្មោះផលប៉ុន្តែ គេហៅតែបងអូន ដល់ពេលទី4នឹងឈ្មោះមុំ ទី5នឹងមិនដឹងឈ្មោះអីទេប៉ុន្តែហៅតូច ចឹងហាសណាស់

កៈ ប៉ុន្តែមីងទីប៉ុន្មានដែរមីង?

ខៈ អូ៎!!មីងទី7ហើយនឹង

កៈ ចឹងមីងទី7ណាមីង?

ខៈ ចា៎!!មីងទី7នឹងហើយខ្ញុំចងចាំអត់អស់ទេពីព្រោះឈ្មោះគាត់នឹងហើយ

កៈ ប៉ុន្តែឥឡូវនឹងនៅសព្វថ្ងៃនឹងមាន2នាក់?

ខៈ ចា៎!!មានសល់2នាក់នឹងស្រីៗៗទាំង2នាក់នឹង

កៈ ប៉ុន្តែមីងបងគាត់រឺមួយក៏គាត់បងមីងដែរ?

ខៈ ខ្ញុំបងគាត់

កៈ ប៉ុន្តែប្អូនរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ មានឈ្មោះពៅ ឈ្មោះជួន ស្រីពៅ

កៈ ឈ្មោះជួន ស្រីពៅអូ៎!បាទ ចឹងមីងមានចងចាំអនុស្សាវរីយ៍អីកាលពីពួកគាត់នៅរស់ហើយនៅក្មេងៗៗដែរទេមីងដូចថាកាលពីអាយុ5-6ឆ្នាំអីធ្លាប់ដើរលេងរឺមួយក៏លេងបិទពួនអីជាមួយគ្នាដែរចឹងហាស?

ខ៖  ធ្លាប់លេងអីអាយុ5-
6ឆ្នាំនឹងអត់ដែរបានលេងអីទេពីព្រោះអីពូកខ្ញុំនឹងជួបគ្នានឹងធំអស់ហើយនឹង

ក៖  អូ៎!!ពេលដែរជួបគ្នានឹងធំៗៗអស់ហើយណាមីង?

ខ៖
ចា៎!!ពេលដែរទៅសម័យពលពតនឹងក៏មិនបានលេងអីជាមួយគ្នាដែរពីព្រោះបងធំជាងចឹង

ក៖  អូ៎!!បាទមីងបាទ?

ខ៖  ចឹងហាសបងគេយកចេញពីនេះទៅបាត់ឆ្ងាយអីចឹងទៅណាស់ហើយ
មីងនៅតែភូមិស្រុកអីចឹងទៅណាស់

ក៖  អូ៎!!បាទមីងប៉ុន្តែយើងធ្លាប់ទៅលេងស្រែអីជាមួយគ្នានឹងក៏យើងអត់ចងចាំដែររឺ
មួយក៏យ៉ាងម៉េចដែរមីធ្លាប់ទៅធ្វើការងារនៅស្រែអីជាមួយគ្នាដែរចឹងហាស?

ខ៖   គឺពេលណុងបងប្រុសរបស់ខ្ញុំនឹងគាត់មកធ្វើកានឹងដូចជាធ្វើជាទាហ៊ាននឹងហាស
ហើយមីងនៅតូចចឹងមីងនៅធ្វើស្រែជាមួយមីងចិញ្ចឹមនឹង
បងប្អូនចិញ្ចឹមនៅជាមួយង្នកស្រុក អ្នកភូមិអីចឹងទៅណាស់

ក៖  បាទមីងបាទ?

ខ៖  ចា៎!!ធ្លាប់មានដែរតើ ប៉ុន្តែជាមួយបងប្រុសខ្លួនឯងបង្កើតនឹងគឺអត់មានទេ

ក៖  អត់មានទេណាមីង?

ខ៖  ចា៎!!គាត់ធ្លាប់ទៅលេងម្តងៗៗចឹងគាត់ធ្លាប់ទៅស្រែបរទេះគោបរអីចឹងទៅណាស់

ក៖  បាទមីងបាទ?

ខ៖
នឹងហើយធ្លាប់ទៅពេលគាត់ចេញពីភ្នំពេញទៅលេងស្រែចឹងជួបមីងចឹងទៅជួបមីងចឹងទៅ
ទៅស្រែទាំងអស់គ្នាចឹងទៅ

ក៖  ទៅដើរលេងដើរលេងទាំងអស់គ្នាចឹងទៅ?

ខ៖  ទៅធ្វើស្រែទៅច្រូតនឹង ដូចថាខែស្ទូងនឹងគាត់ទៅជួយភ្ជួរស្រែ ជួយអីចឹងទៅណាស់

កៈ បាទៗៗមីងបាទ?

ខៈ ពីព្រោះគាត់ចេះដៃរនឹង

កៈ
ចុះមីងគិតថាប្អូនរបស់មីងនឹងដៃររស់នៅជាមួយមីងសព្វថ្ងៃនឹងគាត់នៅណាដៃរមីងឥឡូវ?

ខៈ គាត់នៅបាត់ដំបងប៉ុន្តែឥឡូវនឹងគាត់ទៅនៅថៃហើយនឹងគាត់ទៅធ្វើការងារនៅថៃ

កៈ គាត់ធ្វើការងារអីគេដៃរនៅថៃមីង?

ខៈ គាត់ជាអ្នកពលករចំណាក់ស្រុកទៅនឹង

កៈ អូ៎ៗ!!គាត់ចាស់ហើយនឹងគាត់នៅតែទៅទៀតហោសមីង?

ខៈ ចា៎!! គាត់ទៅយូរដៃរហើយនឹងទៅ

កៈ ប៉ុន្តែប្អូនរបស់មីងនឹងគាត់អាយុប៉ុន្មានដៃរមីង?

ខៈ ប្រហែលជាប្អូនមីង3ឆ្នាំអីនឹង

កៈ អូ៎!!ចឹងមានន័យថាគាត់អាយុសែជាងហើយណាមីង?

ខៈ ចា៎!!គាត់អាយុសែជាងហើយនឹង

កៈ ចុះឪពុករបស់មីងនឹងគាត់មានឈ្មោះអីគេដៃរមីង?

ខៈ ខ្ញុំចងចាំបានថាគាត់ឈ្មោះស៊ុន ឈ្មោះចៅ ស៊ុន

កៈ គាត់ឈ្មោះ ចៅ ស៊ុនហោស?

ខៈ នឹងហើយ

កៈ ប៉ុន្តែបើដល់ពេលឥឡូវនឹងមីងមានដឹងថាគាត់អាយុប៉ុន្មានដៃរទេមីង?

ខៈ អត់ដឹងទេ

កៈ គាត់ចាស់ដៃរហើយណាមីង?

ខ៖
ចាំ!!ប៉ុន្តែមិនដឹងថាគាត់ស្លាប់រឺមួយនៅរស់ទេពីព្រោះគាត់បានបែកនៅក្នុងឆ្នាំ1975នឹងដែរ

ក៖ អូ៎!!ចឹងមានន័យថាកាលពីជំនាន់ណុងមីងនៅរកគ្នាមិនទាន់ឃើញទេណាមីង?

ខ៖ ចាំ!!ទោះបែកគ្នានឹងអត់ដឹងថាអ្នកណាស្លាប់ពិត
ហើយអ្នកណាប៉ុន្តែម៉ាក់របស់មីងនឹងគាត់ស្លាប់
ហើយនឹងគាត់ស្លាប់នៅខេត្តកំពត់អីចឹងហាសណាស់
ហើយបងប្អូននឹងបានស្លាប់នៅនឹងច្រើនដែរ វាចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ ប៉ុន្តែចំណែកប៉ានឹងអត់បានដឹងទេ
អត់ដឹងថាគាត់ស្លាប់រឺមួយក៏នៅរស់ទេណាស់យើងអត់ដឹងទេ

ក៖ ពេលដែរយើងបែកមកយើងបានបាត់ដំណឹងសូន្យតែម្តង?

ខ៖ បានបាត់ដំណឹងសូន្យនឹងទៅ

ក៖ អូ៎!!បាទមីងចុះសំរាប់ឪពុករបស់មីងនឹងគាត់កើតនៅណាមីងមានដឹងទេ?

ខ៖ អត់ដឹងទាំងអស់នឹង

ក៖ ចុះម្តាយរបស់មីងវិញ?

ខ៖ អត់ដឹងដែរ

ក៖ គាត់មានឈ្មោះអីគេដែរមីង?

ខ៖ គាត់ឈ្មោះតាំង ធីសៀង

ក៖ ប៉ុន្តែមីងអត់ដឹងថាគាត់កើតនៅណាទេ?

ខ៖ អត់ដឹងអត់ដឹងទាំងអស់នឹង

ក៖ ចុះមីងមានចងចាំទេថាកាលពីឪពុករបស់មីងនឹងមិនទាន់បានបែកពីពលពតនឹងគិតថាគាត់ធ្វើអីគេដែរមីងសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារដែរមីង?

ខ៖ គាត់ធ្វើការប្រហែលជាគាត់អាចធ្វើការរាជការនឹង

ក៖ គាត់ធ្វើរាជការ ប៉ុន្តែមីងថាគាត់ធ្វើជាទាហ៊ានដែរហីមីង?

ខ៖ ចាំ!!គាត់ប្រហែលជាអាចចឹងនឹង

ក៖ អុំ!!បាទប៉ុន្តែគាត់កាចរឺមួយក៏ស្លូតដែរមីង?

ខ៖ តារបស់ខ្ញុំនឹងប្រហែលជាគាត់ស្លូត គាត់ជាមនុស្សស្លូតនឹង

ក៖ ចឹងហោសមីង?

ខ៖ គាត់ចេះថែរក្សាកូន គាត់ចេះស្រលាញ់កូនចឹងហាគាត់ស្លូត

ក៖ បាទមីង ចុះសំរាប់ម្តាយរបស់មីងនឹងគាត់ធ្វើអីគេកាលពីគាត់នៅរស់ហាសមីង?

ខ៖ វាអត់ដឹងដែរពីព្រោះយើងនៅតូចពេកចឹងវាអត់ដឹងច្បាស់ហាស

ក៖ អូ៎!! ចឹងមីងអត់ដឹងទេណាមីង?

ខ៖ ចាំ!!នឹងហើយៗៗយើងអត់ដឹងច្បាស់ថាគាត់ធ្វើអីទេ

ក៖ ប៉ុន្តែយើងអត់ដឹងថាគាត់កាចរឺមួយក៏ស្លូតទេនឹង?

ខ៖ យើងអត់ដឹងទេនឹង

ក៖ ចុះមីងធ្លាប់មានអនុស្សាវរីយ៍អីកាលនៅជាមួយពួកគាត់ដែរទេមីង?

ខ៖ អត់ដឹងថាមានអនុស្សាវរីយ៍អីផងនឹងពីព្រោះយើងអត់ដឹងដែរនឹង ពីព្រោះតែយើងនៅតូចពេកនឹង

ក៖ អូ៎!!បាទត្រូវហើយនឹងមីង?

ខ៖ នឹងហើយនឹងហើយ

ក៖ ចុះឪពុករបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងដែរទៅមីងទេ?

ខ៖ អត់អត់សោះនឹងហាស

ក៖ អត់ទេហោសមីង?

ខ៖ ចា៎!!អត់ដែរមានទេ

ក៖ ចុះម្ដាយវិញក៏អត់ដែរ?

ខ៖ អត់ដែរនឹងហាស

ក៖ ចុះយាយតាខាងឪពុកនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ អត់ទាំងអស់នឹងនិយាយទៅអត់តែម្ដងនឹងដាច់ផឹងតែម្ដងនឹង

ក៖ ដាច់ខ្សែស្រឡាយហើយណាមីង?

ខ៖ ដាច់ខ្សែអស់ហើយដាច់ខ្សែស្រឡាយផឹងតាំងពីត្រឹមគាត់មកនឹង ត្រឹមពួកខ្ញុំនឹងមកនឹង

ក៖ អូ៎!!ចឹងទាំងម្ដាយនឹងក៏បាត់ដែរណាមីង?

ខ៖ ចា៎!!បាត់ទាំងអស់នឹងនិយាយទៅយើងបាត់ទាំងអស់នឹងតែម្ដងនឹង

ក៖ អូ៎!!ស្ដាយមែនទែនមីង?

ខ៖ បាត់កន្ត៏ដូនតាអីយើងអត់ដឹងហាស
ពេលដែរយើងនៅតូចៗៗអីចឹងទៅយើងបែកឈឹងនឹងតែម្ដងហាសណាស់

ក៖ បាទមីង ចុះមីងមកនៅទីក្រុងភ្នំពេញនឹងយូរនៅមីង?

ខ៖ មីងកាលពីឆ្នាំ1980នឹងមីងគេអោយនៅខេត្តពោសាត់
ចេញមកនឹងនៅខេត្តពោសាត់ហើយបងប្រុស
នឹងគាត់បានចេញមកធ្វើជាទាហ៊ានអីចឹងហាសណាស់

ក៖ បាទមីងបាទ?

ខ៖ នឹងហើយប្រវត្តិរបស់មីងនឹងមានតែ2នាក់បងប្អូនទេគឺបងធ្វើការចឹងទៅ
គាត់ទៅលេងនៅស្រុកម្ដងៗៗចឹងទៅណាស់

ក៖ បាទត្រូវនឹងហើយមីង?

ខ៖ នឹងហើយប៉ុន្តែនៅចន្លោះឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបប៉ុន្មានទេនេះ1985រឺឆ្នាំ1984
បានគាត់យកមីងមកដល់ទីក្រុងភ្នំពេញយកមកនៅតាមហាសនឹងហើយ

កៈ  បាតមីងបាទ?

ខៈ  នឹងហើយចឹង

កៈ  ចឹងមានន័យថាមីងមកនៅទីក្រុងភ្នំពេញនឹងដូចជាអស់34ឆ្នាំហើយនឹងមីង?

ខៈ  ចា៎!!នឹងហើយប៉ុណ្ណឹង

កៈ  ចុះសំរាប់មីងមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេមីង មិញមីងថាមានប្អូនមួយដែររស់នៅក្រៅប្រទេសមែនទេមីង?

ខៈ  ចា៎!!ប្អូនស្រីនឹងនៅថៃ

កៈ  គាត់នៅថៃហើយគាត់ធ្វើជាកម្មករគេណាមីង?

ខៈ  ចា៎!!ប្រហែលជាកម្មករគេហើយនឹង

កៈ  ប៉ុន្តែមានបងប្អូនណាដែរគាត់ទៅនៅប្រទេសផ្សេងទៀតទេមីង?

ខៈ  អត់មានផងនឹង

កៈ  នៅវៀតណាមអីក៏អត់មានដែរណាមីង?

ខៈ  អត់ៗៗអត់មានទេ

កៈ  ចុះសំរាប់ស្វាមីរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ  គាត់ឈ្មោះខឹង សារិន

កៈ  ប៉ុន្តែមីងមានចងចាំថាមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខៈ  ខ្ញុំអត់ចងចាំទេ

កៈ  ប៉ុន្តែដូចជាកូនបងរបស់មីងនឹងគាត់អាយុប៉ុន្មានដែរឥឡូវនឹងមីង?

ខៈ  គាត់អាយុ23-24ឆ្នាំហើយនឹង

កៈ  គាត់អាយុ24ឆ្នាំណាមីង?

ខ៖ ចា៎!!នឹងហើយ

ក៖
ចឹងនៅពេលដែរមីងបានរៀបអាពាហ៍ពិពាហ៍ហើយនឹងតើមីងប៉ុន្មានឆ្នាំដែរមីងទំនេរពោះសិន រឺក៏មីងមានកូនតែម្ដងហោសមីង?

ខ៖ ខ្ញុំទំនេរប្រហែលជា1-2ឆ្នាំអីនឹង

ក៖ អូ៎!!ចឹងមីងប្រហែលជាអាចនឹងការអស់25ឆ្នាំទៅ26ឆ្នាំអីហើយនឹង?

ខ៖ ប្រហែលជាចន្លោះប៉ុណ្ណឹងឯងនឹង

ក៖ អូ៎!!វាយូរដែរណាមីង?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះពេលដែរមីងរៀបអាពាហ៍ពិពាហ៍នឹងដូចជាមីងជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្ដាយរបស់មីងកាត់ជាអ្នករៀបអោយដែរមីង?

ខ៖ អត់មានឪពុកម្ដាយណាដែររៀបចំផងនឹងមានតែបងប្អូននឹង

ក៖ ចឹងមានបងប្អូនជួយរៀបចំអោយទៅ?

ខ៖ មានបងប្អូននឹង

ក៖ ប៉ុន្តែមិនមែនចិត្តយើងផ្ទាល់ទេគឺបងប្អូនជាអ្នកជួយរៀបចំអោយយើង?

ខ៖ ចា៎!!ជួយរៀបចំអោយនឹង

ក៖ ប៉ុន្តែកាលពីពូចូលស្ដីដណ្ដឹងកាលណុងមានជាបណ្ណាការទេមីង?

ខ៖ មានដែរនឹង

ក៖ ពេលណុងដូចជាគេអោយអីទៅមីងដែរ?

ខ៖ ដូចថាបណ្ណាការនឹងដូចថាជាលុយដែរបានចូលដណ្ដឹងយើងនឹង

ក៖ ប៉ុន្តែមីងអាចប្រាប់បានដែរថាប៉ុន្មានដែរកាលពីជំនាន់ណុងហាស?

ខ៖ កាលពីជំនាន់ណុងប្រហែលជា1000$ ជាងនឹង

កៈ អូ៎!!កាលណុង1000$កាលណុងច្រើនណាស់មីង?

ខៈ ចា៎!!!នឹងហើយ

កៈ កាលពីជំនាន់ប៉ែតជាងហីមីងជំនាន់1984ហីមីង?

ខៈ ហ៎ោ!!ចូលជិតកៅហើយនឹងចូលឆ្នាំ1987រឺឆ្នាំ1988ហើយនឹង

កៈ ប៉ុន្តែលុយនៅជំនាន់ប៉ែតជាងក៏នៅតែថ្លៃដែរអ៊ុំ?

ខៈ ចា៎!!នឹងទេប្រហែលជាខ្ទង់1000$ហើយនឹង

កៈ ប៉ុន្តែលុយថ្លៃមាសរៀងថោកមែនទេមីង?

ខៈ ចា៎!!លុយថ្លៃមាសថោកនឹងកាលណុង

កៈ កាលណុងមាសមួយជីដូចជា70រៀលហីមីង?

ខៈ មាសមួយជីនឹងប្រហែលជា20រៀលទៅ30រៀល

កៈ ចុះកាលពូចូលស្ដីដណ្ដឹងមីងនឹងពីមុននឹងពូហើយនឹងមីងធ្លាប់ជួបគ្នាពីមុនដែរទេ ធ្លាប់ស្រលាញ់គ្នាពីមុនដែរទេ?

ខៈ អត់ស្គាល់ផងពេលណុងពេលឃើញនឹងដណ្ដឹងគ្នាតែម្ដងនឹង

កៈ អូ៎!!ពេលដែរគាត់ឃើញមីងនឹងគាត់ប្រាប់ក្រុមគ្រួសារគាត់តែម្ដងហោសមីង?

ខៈ ចា៎!!គាត់ឃើញគាត់ដណ្ដឹងតែម្ដងនឹង

កៈ អូ៎!!បាទ ចុះមីងចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខៈ អត់ចេះទេចេះមើលបានតិចតួចនឹង

កៈ អូ៎!!បាទ ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេមីង?

ខៈ អត់អត់ចេះទេ

កៈ ចុះភាសាវៀតណាម ថៃអីមីងចេះទេ?

ខៈ អត់ទាំងអស់នឹង

កៈ បាទ៎!!ចុះកាលពីជំនាន់មីងរៀននឹងតើមីងរៀនបានថ្នាក់ទីប៉ុន្មានដែរមីង?

ខៈ មីងបានរៀនបានថ្នាក់ទី4ទីអីនឹង?

កៈ ចឹងមីងរៀនបានថ្នាក់ទី4ហោសមីង?

ខៈ នឹងហើយ

កៈ ចុះកាលពីមីងរៀននឹងតើមីងរៀននៅណាដែរមីង?

ខៈ រៀននៅស្រុកភ្នំក្រវ៉ាញ់ នៅខេត្តពោសាត់

កៈ អ៎ូ!!មីងរៀននៅណុងវិញហោសមីង?

ខៈ ចា៎!!នឹងហើយ

កៈ ចឹងឈ្មោះសាលាឈ្មោះចឹងតែម្តងហោសមីង?

ខៈ អត់ដឹងឈ្មោះសាលាឈ្មោះអីគេខ្ញុំបានភ្លេចអស់ហើយនឹង វាយូរឆ្នាំដែរហើយនឹង

កៈ

អ៎ូ!!បាទចុះកាលដែរមីងរៀននឹងដូចជាមានជាមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេ?

ខៈ អត់មានទេធម្មតាៗៗនឹងអត់មានអ្នកណាស្និទ្ធិស្នាលធម្មតានឹង

កៈ គ្រាន់តែជាមិត្តភក្តិធម្មតាទេណមីង?

ខៈ ចា៎!!នឹង

កៈ អ៎ូ!!ចុះមីងគិតថាកាលជាមួយមិត្តភក្តិនឹងមីងធ្លាប់បានលេងជាមួយគ្នាដែរទេនៅសាលារឺមួយក៏ពេលតាមផ្លូវមកផ្ទះអីនឹងហាស?

ខៈ អត់ទេធ្លាប់លេងលោតកៅស៊ូ នៅសម័យនឹងលេងត្រើស

កៈ លេងកូនប៉ែងលេងអីនឹងហោសមីង?

ខៈ លេងបាយខំ លេងអាបាយខំហាស

កៈ បាទៗៗមីងខ្ញុំស្គាល់

ខ៖ លេងត្រីសអាត្រីសគេរាប់

ក៖ បាទមីងបាទស្គាល់មីងខ្ញុំស្គាល់ដែរ

ខ៖ នឹងហើយធ្លាប់តែលេងល្បែងនឹង

ក៖ អូ៎!!បាទប៉ុន្តែធ្លាប់ទៅស្រែជាមួយគ្នាដែរតើហីមីង?

ខ៖ អត់ទេគេទៅផ្សេងនឹងយើងទៅផ្សេងចឹងទៅណាស់

ក៖ អូ៎!!បាទមីង ចុះមីងគិតថាមីងធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់មីងដែរចឹងហាស តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ការងាររបស់ខ្ញុំធ្លាប់តែធ្វើការប្រើពលកម្មធ្វើការនៅរោងចក្រនឹងធ្វើអីចឹងទៅណាស់

ក៖ អូ៎!!បាទមីងបាទ ប៉ុន្តែធ្លាប់ទៅធ្វើការងារនៅស្រែដែរតើហីមីង?

ខ៖ ចា៎!!ធ្លាប់កាលពីខ្ញុំនៅធ្វើស្រែនឹងខ្ញុំធ្វើស្រែចឹងទៅ
ដល់ពេលដែរឈប់ពីនៅធ្វើស្រែនឹងមកភ្នំពេញនឹង ក៏ប្តូរអាជីពអីផ្សេងចឹងហាស

ក៖ អូ៎!!បាទមីងបាទ ចុះមីងគិតថាស្រែចំការមីងធ្លាប់ទៅធ្វើមែនទេមីង?

ខ៖ ចា៎!!ធ្លាប់

ក៖ ប៉ុន្តែមីងគិតថាបើកអាជីវកម្មនឹងតើមីងធ្លាប់បើកអីទេមីង?

ខ៖ អត់អត់ធ្លាប់ផងនឹង

ក៖ ប៉ុន្តែមីងធ្លាប់ទៅចិញ្ចឹមសត្វអីទេដូចជាចិញ្ចឹមគោ ក្របីអីចឹងហាស?

ខ៖ អត់ដែរចិញ្ចឹមផង អត់ចូលចិត្តចិញ្ចឹមទេ

ក៖ អូ៎!!ចឹងអត់ដែរទេណាមីង?

ខ៖ ចា៎!!អត់ដែរទេ

ក៖ ចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរនៅក្នុងជីវតរបស់មីងដែរទៅ តាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខ៖ ធ្លាប់ផ្លាស់ប្តូរដូចថាយើងមកពីក្មេងនឹងមកមួយដំណាក់ៗៗធម្មតាចឹងហាស អត់មានអីផ្លាស់ប្តូរអីធំដុំនឹងទេដូចថាគ្រាន់តែយើងដើរមួយដំណាក់បន្តិចៗៗអីចឹងទៅណាស់

ក៖ អូ៎!!ចុះមីងគិតថាជីវភាពរបស់មីងនឹងយ៉ាងម៉េចដែរចឹងហាស?

ខ៖ ជីវភាពនឹងធម្មតានឹង

ក៖ ប៉ុន្តែសុខភាពអីនឹងឥឡូវនឹងធម្មតាដែរណាមីង?

ខ៖ ចា៎!!នឹងហើយវាធម្មតានឹងវាអត់ទៀតទាត់ហាស

ក៖ បាទមីងបាទ?

ខ៖ រឿងសុខភាពមួយយើងអត់អាចថាយើងជារហូតនឹងទេ ហើយនឹងវាមិនឈឺរហូតអីទេគ្រាន់តែថាវមិន ទៀងទាត់អីចឹងហាស

ក៖ បាទមីងបាទត្រូវហើយនឹង?

ខ៖ វាចឹងហាស

ក៖ បាទចុះមីងគិតថាមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖ អត់មានប្រាកដថាម្ហូបអីទេ អោយតែមានសំរាប់មួយពេលៗៗនឹងគឺទទួលយកបានហើយ

ក៖ ប៉ុន្តែមីងមានធ្លាប់?

ខ៖ មិនថាអត់មានម្ហូបអីឆ្ងាញ់នឹងគឺអត់ទេនឹងអត់ញ៉ាំបាយអីចឹងហាស មិនមែនមានន័យថាអីទេមានម្ហូបនឹងចេះតែញ៉ាំទៅ

ក៖ បាទមីងបាទនឹង?

ខ៖ សំរាប់រស់មួយថ្ងៃៗៗចឹងទៅណាស់

ក៖ ប៉ុន្តែមីងធ្លាប់គិតមួយថាមីងម្ហូបអីគេមួយដែរមីងគិតថា មីងតែងនឹកឃើញចង់ញ៉ាំវាដូចថាស្ងោរបង្កង់អីចឹងហាស?

ខ៖ អត់អត់មាននឹកឃើញអីផងនឹង

ក៖ ចឹងហោសមីង?

ខ៖ ទោះមានក៏មានទៅបើអត់ក៏អត់ចឹងទៅណាស់
មិនមានការចាប់អារម្មណ៍អីទេនិយាយទៅជីវិតធម្មតា
នឹងមិនមានត្រូវការអីមិនចាំបាច់អោយតែខ្លួនឯងអីចឹងទៅណាស់

ក៖ ស្អីក៏បានដែរណាមីង?

ខ៖ ស្អីក៏បានដែរនឹងមានអីនឹងអោយតែថាត្រូវភ្លាមអំបិលក៏បានដែរនឹង

ក៖ យើងមានអីញ៉ាំណាងហើយណាមីង?

ខ៖ ចាំ!!អត់ដែរគិតទៅរកបង្គង់ បង្គាអីទេអីណាណីអីទេអត់មានទេ

ក៖ អូ៎!!បាទមីងបាទត្រូវហើយមីង
ចុះមីងគិតថាល្បែងប្រជាប្រិយ៍អីដែរមីងចូលចិត្តលេងតាំងពីក្មេង ដែរចឹងហាសមីង?

ខ៖ មីងចូលចិត្តលេងមើលប្រជាប្រិយ៍នៅសម័យចូលឆ្នាំនឹង
ចូលចិត្តលេងឈូងនឹងចូលចិត្តលេងអង្គុញ

ក៖ មានលាក់កន្សែង?

ខ៖ មានលាក់កន្សែង អាកាន់ស្លឹកឈើនៅដៃហោស

ក៖ លេងដណ្ដើមស្លឹកឈើណាមីង?

ខ៖ នឹងហើយមានស្វាដណ្ដើមទីអីចឹងទៅណាស់

ក៖ អូ៎!!បាទមីងបាទ?

ខ៖ លក្ខណះបុរាណពីដើមហោស

ក៖ ប៉ុន្តែភាគច្រើននឹងទៅលេងនៅណាដែរមីង?

ខ៖ លេងនៅក្នុងភូមិលេងនៅមុខផ្ទះអីចឹងទៅណាស់
នឹងហើយដល់ដែរចូលឆ្នាំនឹងទៅវត្តទៅឈរមើល គេឯងចឹងទៅណាស់ គេលេងទាញព្រាត រឺមួយក៏លេងឈូងអីចឹងទៅណាស់

ក៖ ប៉ុន្តែយើងអត់ទៅលេងនឹងគេទេ?

ខ៖ យើងអត់លេងទេយើងគ្រាន់តែឈរមើលចឹងទៅណាស់

ក៖ យើងលេងតែនៅផ្ទះទេណាមីង?

ខ៖ នឹងហើយចុះតូចៗជាងគេនឹងទៅលេងជាមួយគេយ៉ាងម៉េចនឹងកើត

ក៖ យើងលេងអត់ឈ្នះគេ?

ខ៖ យើងលេងអត់ឈ្នះគេចឹងគេជាន់ចឹងទៅ

ក៖ ចុះមីងគិតថាមីងចេះច្រៀងចំរៀងទេ?

ខ៖ អត់អត់ចេះទេ

ក៖ ប៉ុន្តែមីងចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ ចូលចិត្តពេលខ្លះដែរនឹងពេលមានអារម្មណ៍ល្អទៅចូលចិត្តស្តាប់ចឹងទៅ
ពេលអត់ក៏អត់ចឹងទៅ

ក៖ ជាបទសម័យរឺមួយក៏បទបុរាណដែរមីង?

ខ៖ បទបុរាណ

ក៖ ប៉ុន្តែសំរាប់ចំណង់ចំណូលចិត្តរបស់មីងតែម្តងនឹងមីងចូលចិត្តធ្វើអីគេដែរ
ជាមើលទូរទស្សន៍ ស្តាប់ចំរៀង រឺក៏ស្តាប់ធិមអីចឹងទៅណាស់?

ខ៖ ពេលបច្ចុប្បន្ននឹងចូលចិត្តស្តាប់ធិម

ក៖ ចូលចិត្តស្តាប់ធិមច្រើនជាងណាមីង?

ខ៖ ចា៎!!ចូលចិត្តនឹង

ក៖ អ៊ូ!!បាទមីងចុះមីងគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់មីងនឹងចេះលេងឧបរកណ៍ភ្លេងដែររឺទេមីង?

ខ៖ អត់ផងនឹង

ក៖ ទាំងភ្លេងបុរាណនឹងភ្លេងសម័យក៏អត់ចេះដែរ?

ខ៖ អត់ចេះទេ

ក៖
អ៊ូ!!បាទចុះផ្ទះរបស់មីងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសថាតើពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខ៖ ពីក្មេងយើងធ្លាប់រស់ជនបទមានផ្ទះឈើផ្ទះអីនឹងធម្មតាចឹងទៅណាស់នឹងហើយ

ក៖ ដល់ពេលឥឡូវនឹងមីងបានផ្ទះថ្ម?

ខ៖ នឹងហើយចាំ

ក៖ មីងផ្លាស់ប្តូរ ចុះមីងមានដឹងថាផ្ទះរបស់មីងនឹងនរណាគេជាអ្នកសាងសងដែរមីងយើងជួលគេរឺក៏យើងធ្វើដោយខ្លួនឯងដែរមីង?

ខ៖ យើងជួលជាង

ក៖ យើងជួលជាងហោសមីង
ចឹងក្រុមគ្រួសាររបស់មីងនឹងអត់មាននរណាគេមួយចេះធ្វើផ្ទះទេ?

ខ៖ អត់អត់ទេៗ

ក៖
ចុះមីងមានដឹងថាផ្ទះរបស់មីងគេធ្វើនឹងគេប្រើឧបករណ៍អីគេសំរាប់សាងសងដែរទេមីង?

ខ៖ មានស៊ីម៉ង់ មានខ្សាច់ មានដែកអីចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ នឹងហើយមានថ្មអីចឹងទៅណាស់ ហើយនឹងដាក់គ្រឹះដាក់អីវានឹង

កៈ បាទមីងចុះមីងគិតថាមីងមានជំនាញអីដែរមីងចេះស្ទាត់ជំនាញដែរទេមីង?

ខៈ មិនមានអីចេះពិតប្រាកដទេជំនាញរាល់ថ្ងៃនឹង

កៈ អូ៎!!បាទមីង
ចុះមីងគិតថាឪពុកម្ដាយរបស់មីងនឹងគាត់មានបានបង្រៀនពីជំនាញអីមីងដែរទេ
ដូចជាវេញវល្លិ៍ កូរស្ករត្នោត ធ្វើផ្ដៅ ធ្វើជាកន្ទេលអញ្ចូត?

ខៈ
ទេអត់ដែរបានបង្រៀនអីទេពីព្រោះពួកយើងពេលវេលាដែរបានជួបជាមួយគាត់នឹងតិចពេក
ហោស

កៈ បាទមីងបាទចឹង?

ខៈ យើងជួបជាមួយគាត់នឹងយើងនៅវ័យកុមារតូចខ្លាំងហាស

កៈ ចឹងគាត់ក៏មិនបានធ្វើអីជាមួយយើងទេហោសមីង?

ខៈ យើងក៏មិនបានធ្វើអីគេដែរ យើងក៏អត់ដែរ

កៈ
ចុះមីងអាចប្រាប់ពីពេលលំបាកថាមីងលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានដែរទេ
មីង ធ្លាប់មានបញ្ហាលំបាកអីគេខ្លះដែរចឹងហាសមីង?

ខៈ អូ៎!!ឆាកជីវិតកូនកំព្រានឹងលំបាកហើយ

កៈ ចុះមីងគិតថាកាលពីក្មេងនឹងមីងយ៉ាងម៉េចដែរទៅមីងមានការលំបាកអីគេដែរទៅ?

ខៈ លំបាកគ្រាន់តែថាយើងវាអត់មានឪពុកម្ដាយបង្កើត
នឹងអត់មានបងប្អូននៅជុំវិញយើងចឹងទៅណាស់

កៈ បាទមីងបាទ?

ខៈ គ្រាន់តែថាយើងវានៅក្មេងចឹងទៅណាស់ ធម្មតាទេជីវិតរបស់យើងនៅកូនក្មេងនឹង
ជាមិនសូវជាគិតអីម៉ត់ចត់ម៉ុន្មានដែរទេ
ប៉ុន្តែគ្រាន់តែថាពេលណាដែរលំបាកនឹងយើងចង់បានឪពុកនឹង
ម្ដាយអីដូចគេចឹងទៅណាស់

កៈ បាទមីងបាទ?

ខៈ ចង់បានដូចគេដូចឯងអីចឹងទៅណាស់

កៈ បាទមីងនឹង?

ខៈ នឹងហើយគ្រាន់តែគិតចឹងពិបាកចិត្តតែប៉ុណ្ណឹងទេ

កៈ ចុះមីងគិតថាកាលពីជំនាន់ពលពតនឹងមីងនៅតូចហើយណាមីង?

ខៈ ចាំ!!មីងនៅតូចមីងគេអោយជួយមើលកូនក្មេងអីចឹងទៅណាស់នឹងហើយ

កៈ ចុះពេលណុងមីងនៅកងកុមារមែនមីង?

ខៈ មិនច្បាស់ថានៅក្នុងកុមារទេនៅតាមការដ្ឋានអីចឹងទៅណាស់

កៈ អ៎ូ!!បាទមីងបាទ?

ខៈ នៅតាមភូមិតាមអីចឹងទៅណាស់

កៈ ប៉ុន្តែពេលណុងគេអោយមីងទៅណាដែរទៅនៅណា?

ខៈ នៅផ្ទះជាមួយម៉ែចិញ្ចឹមអីចឹងទៅណាស់
ដល់ពេលដែរដល់ម៉ោងបាយម៉ោងអីចឹងយើងទៅញុំាបាយ ទៅអីចឹងទៅ
គេចង់អោយយើងធ្វើអីៗចឹងយើងចេះតែជួយគេចឹងទៅ អត់មានថាយើងទៅណាមួយពិត
ប្រាកដអីចឹងទៅណាស់

កៈ ប៉ុន្តែនៅខេត្តណាវិញមីងពេលណុង?

ខៈ នៅខេត្តពោសាត់

កៈ នៅខេត្តពោសាត់ដដែរហោសមីង?

ខៈ ចាំ!!នៅខេត្តពោសាត់ នឹងនៅស្រុកភ្នំក្រវាំញ់

កៈ ប៉ុន្តែបីឆ្នាំនឹងគឺយើងធ្វើចឹងរហូតណាមីង?

ខៈ ចាំ!!បីឆ្នាំនឹង

កៈ ប៉ុន្តែឪពុកម្តាយរបស់មីងនឹងគាត់បានស្លាប់នៅក្នុងណុងដែររឺមួយក៏យ៉ាងម៉េចដែរទៅ?

ខ៖ ខ្ញុំអត់ដឹងថាគាត់ស្លាប់រឺយ៉ាងម៉េចទេពេលណុងគឺបែកចេញអត់តែម្តងនឹង

ក៖ បងប្អូនក៏បែកចេញដែរណាមីង?

ខ៖ ចាំ!!បែកចេញអស់នឹងពីគ្នាតែម្តងនឹង

ក៖ អូ៎!!បាទគ្រាន់តែយើងដឹងថានៅពោសាត់នឹង3ឆ្នាំ 8ខែនឹងគឺយើងធ្វើតែចឹងរហូត?

ខ៖ ចាំ!!

ក៖ ចុះរបបអាហារនឹងដូចគេដែរតើហីមីង?

ខ៖ សម័យពលពតនឹងហោស?

ក៖ បាទ!!មីងបាទ

ខ៖ មិនដូចទេពេលខ្លះយើងបបរ មានស្អីទេខ្ញុំចាំមិនសូវបានដែរកាលពីនៅក្មេងនឹង ពេលខ្លះយើងមានបាយញុំាអីដែរចឹងទៅណាស់

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ប៉ុន្តែមិនដឹងថាវាប្រើរបៀបយ៉ាងម៉េចដែរនឹងវាភ្លេចដែរ?

ក៖ អូ៎!!បាទមីង?

ខ៖ មានបបរអីចឹងទៅណាស់នឹងហើយ

ក៖ ចុះមីងគិតថាពេលដែរដាច់ពលពតទៅនឹងមានការលំបាកមួយតង់ទៀតមែនទេមីង ដូចជាយើងត្រូវការរកលុយដើម្បីទិញផ្ទះ ទិញអីនៅ?

ខ៖ អត់ទេអត់មានពិបាកទេបែកពីសម័យពលពតនឹងមកគឺយើងមានដី មានផ្ទះសំបែងពេលណុងសំបូរ ណាស់មិនសូវចេះខ្វះដីធ្លីអីទេនឹង

ក៖ អូ៎!!ពេលណុងមានហើយហោសមីង?

ខ៖
ចាំ!!មិនចេះខ្វះទេដីអោយតែយើងនៅស្រុកស្រែប៉ុន្តែនៅទីក្រុងនឹងយើងអត់ដឹងទេណាស់

ក៖ បាទមីងបាទ?

ខ៖ ប៉ុន្តែបើអោយទៅនៅស្រុកស្រែវិញចង់បានដីប៉ុន្មានក៏មានដែរមិនចេះខ្វះទេ

ក៖ បាទមីងបាទ?

ខ៖
នឹងហើយយើងចង់ធ្វើអីអោយតែយើងមានកំលាំងចង់ទៅធ្វើផ្ទះនៅណាក៏បានដែរមិនខ្វះទេ អោយតែយើងចង់ធ្វើនឹង

ក៖ បាទមីងបាទ?

ខ៖ នឹងហើយសំបូរណាស់

ក៖ ចុះមីងគិតថាមីងឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរទៅមីង
ឆ្លងកាត់ដែរមីងលំបាកពីក្មេង រហូតមកដល់ឥឡូវនឹងហាស
ឆ្លងកាត់វាយ៉ាងម៉េចដែរជំនះឧបសគ្គនឹងហាស?

ខ៖ ទេធម្មតានឹងដូចថាពេលណុងវាអត់សម័យអត់ទំនើបដូចឥឡូវនឹងហាស
អត់គិតថាមានការពិបាក ខ្លាំងអីទេនឹង

ក៖ បាទមីងបាទ?

ខ៖ ពីព្រោះមិនទាន់ស្ទូវចាយលុយមិនទាន់មានរបស់របរទំនើបអីចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ ហើយយើងនឹងកមិនដែរខ្វល់អីទេ សំរាប់មួយថ្ងៃនឹងបានមួយថ្ងៃ
សំរាប់មួយថ្ងៃនឹងបានមួយថ្ងៃទៅនឹងហាស

ក៖ យើងគិតមួយថ្ងៃបានមួយថ្ងៃចឹងណាមីង?

ខ៖ នឹងហើយកាលណុងយើងនៅក្មេងៗនឹងយើងមិនដែរស្ទូវខ្វល់ខ្វាយអីទេធំដុំទេ

ក៖ អ្ហូ!!ល្អហើយណាមីង?

ខ៖ នឹងហើយ

ក៖ ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់មីងដែរចឹងហាស?

ខ៖ ដូចជាអត់មានទេ

ក៖ ចុះសំរាប់ពេលដែរមីងការនឹង?

ខ៖ ការនឹងក៏ជារឿងធម្មតាដែរនឹងដូចជាអត់មានរឿងអីទេ ជីវិតធម្មតាអីចឹងទៅនឹងហើយ

ក៖ បាទមីង ចុះមីងគិតថាពេលដែរមីងបានជួបជុំបងប្អូនអីមីងគិតថាពេលណុងសប្បាយដែរទេមីង?

ខ៖ ចាំ!!ធម្មតានឹងមិនថាធ្វើណាអោយសប្បាយអស់អស្ចារ្យអីទេ

ក៖ អត់មានទេចឹង?

ខ៖ គិតទៅថាជីវិតនឹងវាសាមញ្ញនឹងជួបក៏ប៉ុណ្ណឹង មិនជួបក៏ប៉ុណ្ណឹង

ក៖ បាទមីង ចុះមីងគិតថាមីងចង់ធ្វើអីគេមួយដែរទេពេលដែរមីងធំឡើងនឹងមីង?

ខ៖ ប្រាថ្នាដែរប៉ុន្តែវាអត់បានទេ

ក៖ ប៉ុន្តែពេលណុងមីងចង់ធ្វើអីគេដែរទៅ?

ខ៖ ចង់ធញរើការងារអីនឹងប៉ុន្តែគ្រាន់តែថាយើងមិនបានរៀនសូត្រនឹង

ក៖ អូ៎!!បាទមីងបាទ?

ខ៖ យើងស្តាយដែរនឹងចឹងរាល់ថ្ងៃនឹងខំប្រឹងប្រែងនឹងប្រាប់កូននឹងថា ការពារជីវិតកុំអោយស្តាយក្រោយ កុំអោយដូចម៉ាក់អីចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ អោយខំរៀនសូត្រនឹងពីព្រោះជីវិតរបស់ម៉ាក់នឹងម៉ាក់ប្រាថ្នាចង់បានធ្វើការអីមួយរឺមួយក៏ធំថ្លៃថ្នូរអីចឹង ទៅណាស់

ក៖ ប៉ុន្តែយើងទៅអត់រួច?

ខ៖ នឹងហើយខំប្រឹងប្រែងរៀនសូត្រអីចឹងទៅណាស់
ពេលដែរមិនបានជោគជ័យចឹងចេះតែប្រាប់កូនថា
អោយខំប្រឹងប្រែងរៀនសូត្រអោយធ្វើតាមនឹង ពេលវេលាមិននៅចាំយើងទេ

ក៖ ត្រូវហើយមីងត្រូវហើយ

ខ៖ យលងប្រាប់កូនចឹងហាសថាកូនខំទៅដើម្បីអោយមានអនាគត់ល្អ
បើសិនជាកូនអត់ខំរៀននឹង អោយបានចេះទេ
ថ្ងៃណាមួយគេអោយទៅធ្វើការងារអីមួយយើងធ្វើអត់កើតនឹងយើងស្តាយនឹង
នឹងយើងប្រាប់កូនចឹង

ក៖ នឹងជាពាក្យផ្តែផ្តាំរបស់មីងទៅកូនណាមីង?

ខ៖ ចាំ!!ដែរនិយាយថានិងជាជីវិតរបស់ម៉ាក់ផ្ទាល់ហើយនឹង
ចឹងកូនត្រូវតែជឿម៉ាក់និយាយនឹងមិនមែនចេះតែនិយាយទេ ម៉ាក់និយាយការពិតនឹង

ក៖ ប៉ុន្តែនៅក្នុងសង្គមជីវិតពិតនឹងគឺវាមានដឹងមែន?

ខ៖ នឹងហើយជីវិតពិតគឺវាចឹងកូនមើលឃើញហើយ
ហើយដល់ពេលរាល់ថ្ងៃនឹងម៉ាក់ក៏នៅតែសោកស្តាយចឹងដែរនឹងហាស

ក៖ បាទមីងបាទ?

ខ៖ នឹងហើយនៅតែស្តាយពេលដែរឃើញក្មេងៗទៅរៀនអីនឹង
តែងតែនឹកឃើញថាបើអាចវិលត្រលប់ ទៅរកដើមវិញហាសយើងនឹងប្រាប់គេ

ក៖ យើងនឹងបកក្រោយវិញនឹងហោសមីង?

ខ៖ នឹងហើយយើងនឹងបកក្រោយវិញ

ក៖ ខំប្រឹងរៀនសូត្រ?

ខ៖ នឹងហើយយើងស្តាយដែរ

ក៖ បាទមីងបាទ?

ខ៖ ស្ដាយតែវាមិនដឹងថាធ្វើនម៉េចវាស្ដាយប៉ុន្តែវាជាអតីតនឹងយើងបោះវាចោលទៅ
ត្រូវមកគិតកូនជំនាន់ក្រោយអោយគេ

ក៖ បាទយើងត្រូវគិតចឹង?

ខ៖
នឹងហើយកអោយគេល្ងង់នឹងកុំអោយគេអីចឹងទៅណាស់ពិភពលោកនឹងធំទូលាយណាស់

ក៖ បាទមីងបាទ?

ខ៖ គេត្រូវការអ្នកចេះដឹងទេ
បើយើងនឹងមិនចេះដឹងនឹងពិបាកណាស់ទៅណាក៏ពិបាកដែរនឹង

ក៖ បាទមីងចុះបើសិនជាអោយមីងផ្ដែផ្ដាំអោយពួកគាត់ជៀសវៀងវិញហាស
តើមីងចង់អោយគាត់ជៀសវៀងអីគេដែរកូនចៅរបស់មីងនឹង?

ខ៖ ជៀសវៀងពីគ្រឿងញៀន ជៀសវៀងពីគ្រឿងស្រវឹងនឹង

ក៖ បាទមីងបាទ?

ខ៖ អត់ចង់បានទេហើយនឹងល្បែងអីសូមអោយកូននឹងជៀសវៀងអោយផុតទៅនឹងហាស
យើងខំប្រឹងប្រែងរាល់ថ្ងៃនឹងហាស

ក៖ បាទមីងធ្វើចឹងអត់ល្អនៅក្នុងសង្គមទេណាមីង?

ខ៖ ចាំ!!វាអត់ល្អទេវាអត់ល្អសោះនឹងហាសកុំអោយកូនដើរចូលរឿងនឹងវាស្អប់បំផុតនឹង

ក៖ បាទមីងត្រូវហើយនឹងមីង ចុះមានអីទៀតទេមីង?

ខ៖ អត់មានអីទេមានតែពាក្យប៉ុណ្ណឹងទេ

ក៖
បាទមីងជាចុងក្រោយនឹងខ្ញុំសូមអរគុណច្រើនមីងដែរមីងបានដែរបានពិភាក្សាពីប្រវត្តិមួយ
នឹងសំរាប់ ខ្ញុំហើយខ្ញុំនឹងតំកល់ទុកអោយមីងនៅក្នុងសាលាចឹងហាសមីង
បាទអរគុណច្រើនមីង៕៕៕